សារព័ត៌មាន

# ខ្មែរម្ចាស់ស្រុក

Khmer Machas Srok News

សារព័ត៌មានចេញផ្សាយប្រចាំថ្ងៃ

ឆ្នាំទី ០៤ លេខ ៦៦១ ចេញផ្សាយថ្ងៃ សុក្រ ទី ២១ ខែ ឧសភា ឆ្នាំ ២០១០

## យឹម សុវណ្ណ : លោក ឱម យ៉ិនទៀង គ្មានស្នាដៃក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយទេ



លោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សសមរង្ស៊ី



លោក ឱម យ៉ិនទៀង ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

ដោយ : មាឌ្យ ឧត្តម

នៅពេលដែលអ្នកកាសែតបានសួរនាំលោក *យឹម សុវណ្ណ* អ្នកតំណាងរាស្ត្រមណ្ឌលភ្នំពេញ និងជាអ្នកនាំពាក្យគណបក្សសមរង្ស៊ីពីការតែងតាំងលោក *ឱម យ៉ិនទៀង* ជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយថ្មីរបស់រដ្ឋាភិបាលលោក *ហ៊ុន សែន* នោះ លោកបានមានប្រសាសន៍ថា លោកគ្មានជំនឿថានឹងមាន

តទៅទំព័រទី៤ ន

## យួនផ្តល់សញ្ជាតិឱ្យពលរដ្ឋខ្មែរនៅតាមព្រំដែនដើម្បីកុំឱ្យតវ៉ារឿងបាត់បង់ដីស្រែ



ភរិយាលោក ព្រំ ជា



ប្រជាពលរដ្ឋនៅតាមបណ្តោយព្រំដែនខ្មែរ-យួនក្នុងខេត្តស្វាយរៀង

ដោយ : វាសនា

បន្ទាប់ពីប្រជាពលរដ្ឋខ្មែរជាច្រើនគ្រួសារ នៅភូមិកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង និយាយថាពួកគាត់បាត់បង់ដីស្រែ ដោយសារការ បោះបង្គោលព្រំដែន រវាងកម្ពុជា ជាមួយយួន ជាពិសេស

តទៅទំព័រទី២ ឡ

## សុន ឆ័យ : វប្បធម៌រួមចំណែកធ្វើឱ្យមានអំពើពុករលួយបាត់ប្រាក់ចំណូលរដ្ឋជាគ្រោះថ្នាក់សម្រាប់កម្ពុជា



លោក សុន ឆ័យ ប្រធានក្រុមអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី



លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីប្រទេសកម្ពុជា

ដោយ : យុទ្ធ ពន្ធ

ស្ថានភាពនៃប្រទេសកម្ពុជាបច្ចុប្បន្នដែលស្ថិតនៅក្រោមការត្រួតត្រាដឹកនាំដោយគណបក្សប្រជាជនហើយដែលអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិមានកង្វល់ បារម្ភយ៉ាងខ្លាំងចំពោះអំពើពុករលួយដ៏រាលដាលអំណាចហួរហៀរនៃបុគ្គលត្រួតត្រាប្រទេស ក្នុងស្ថានភាពដែលប្រជារាស្ត្រក្លាយជាជនរងគ្រោះសព្វគ្រប់

តទៅទំព័រទី៤ ជ

## នាយកដ្ឋានមធ្យមសិក្សាចំណោះទូទៅនៃក្រសួងអប់រំកំពុងជុំភ្លឺនមិនសូវស្រួល



លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ



រដ្ឋមន្ត្រីក្រសួងអប់រំ អ៊ឹម សិទ្ធី

ដោយ : វិសាល

ក្រុមមន្ត្រីមួយចំនួនដែលនៅបម្រើការងារតាមនាយកដ្ឋានក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា បានស្នើយ៉ាងទទូចឱ្យលោក*រ៉ុង ឈុន* ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យជួយអន្តរាគមន៍ទៅរដ្ឋមន្ត្រី

តទៅទំព័រទី២ ញ

## រដ្ឋាភិបាលក្រុងបាងកកចោទប្រកាន់ទីប្រឹក្សាម្នាក់របស់ហ៊ុនសែនថាជាមេភេរវករ

ដោយ : សីហា

ប៉ុន្មានម៉ោងក្រោយពីកម្លាំងយោធាប្រើធមិក្តៅ សំអាតអ្នកធ្វើបាតុកម្មប្រឆាំង នឹងរដ្ឋាភិបាលមក លោក*អាប់ភីស៊ិត វ៉ាចាជីវ៉ា* នាយករដ្ឋមន្ត្រី សៀមបានចោទប្រកាន់លោក*ថាក់ស៊ីន ស៊ីណាវ៉ាត្រា* ថា ជាមេភេរវករ

តទៅទំព័រទី៣ ស



លោក ថាក់ស៊ីន ត្រូវបានរដ្ឋាភិបាលក្រុងបាងកកចោទថាជាមេភេរវករ

## អាជ្ញាធរមិនឱ្យក្រុមអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីសួរសុខទុក្ខអ្នកស្រីមាសស្រីនិងលោកព្រំជា



លោកស្រី កែ សុវណ្ណរតន៍ អគ្គលេខាធិការគណបក្សសមរង្ស៊ី



លោក អង្គវង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌



ប្រជាពលរដ្ឋនៅស្រុកជីក្រែង ត្រូវអាជ្ញាធរបាញ់ឱ្យរបួសក្នុងជម្លោះដីធ្លី



កសិករមាសស្រីត្រូវបានជាប់ពន្ធនាគារដោយសារដកបង្គោលតម្រុយចេញពីដីស្រែរបស់ខ្លួន

ដោយ: សុរិយាវិរិយ៍

ក្រុមអ្នកតំណាងរាស្ត្រ គណបក្សសម រង្ស៊ី ត្រូវបានហាមឃាត់មិនអោយទៅសួរសុខទុក្ខប្រជាកសិករ២រូបនៅពន្ធនាគារខេត្តស្វាយរៀង ។ ការហាមឃាត់នេះ បន្ទាប់ពីអគ្គលេខាធិការគណបក្សសម រង្ស៊ី បានស្នើម្តងហើយម្តងទៀត ទៅឆ្នាំពន្ធនាគារ ទៅក្រសួងមហាផ្ទៃ និងទៅស្ថាប័នពាក់ព័ន្ធ ដើម្បីអាច

តទៅទំព័រទី២ ម

## ដំណឹងលក់ដី

យើងខ្ញុំមានដីមួយកន្លែងទំហំ ៣០ម x ៣០ម នៅទល់មុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ ។ ទីតាំងដីនោះនៅចម្ងាយប្រមាណ៥០០ម៉ែត្រពីភ្លើងស្តុបព្រលានយន្តហោះ ជាប់កាច់ជ្រុងផ្លូវបេតុង ស្ថិតនៅក្នុងភូមិចំការឪឡឹក សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានទឹក និងភ្លើងរដ្ឋ ។

ទីតាំងនៃដីនោះស្ថិតនៅទីប្រជុំជន មានផ្សារ រោងចក្រ អាចធ្វើផ្ទះសំណាក់ ខុនដូ ហើយលក់ក្នុងតម្លៃ ៦៥ម៉ឺនដុល្លារអាមេរិក ដែលជាតម្លៃអាចនិយាយចរចាគ្នាបាន ។ បើអតិថិជនចាប់អារម្មណ៍ សូមទំនាក់ទំនងទូរស័ព្ទលេខ **០១៦ ២៩ ៥៦ ៥៦** ។

សូមអរគុណ

## សម្តេចឪសព្វព្រះទ័យទទួលយកលោកខែក វ៉ាន់ឌី ជាទីប្រឹក្សាផ្ទាល់របស់ព្រះអង្គ

ដោយ : ជ័យ តារា

សម្តេចឪព្រះ*នរោត្តមសីហនុ* បានយាងចូលនិវត្តន៍ កាលពីខែតុលា ឆ្នាំ២០០៤ ។ ក្រោយពីការយាងចូលនិវត្តន៍ រយៈពេល ៦ឆ្នាំកន្លងទៅនេះ ព្រះអង្គគ្មានទីប្រឹក្សាទេ ។ ប៉ុន្តែព្រះអង្គមានមន្ត្រីជំនួយការ នៅព្រះរាជខុទ្ទ

តទៅទំព័រទី៣ ខ



លោក ខែក វ៉ាន់ឌី នឹងក្លាយទៅជាទីប្រឹក្សាព្រះមហាវីរក្សត្រ

*បរិយាយថ្ងៃនេះ*

## នយោបាយចតុកោណរបស់ហ៊ុនសែនធ្វើឱ្យរាស្ត្រជាម្ចាស់ដីធ្លីក្លាយជាទាសករ

ដោយ : មាឌ្យ ច្រាឆ្មា

តាមពិតទៅនេះជាបញ្ហាមិនមែនសម្រាប់តែមនុស្សកាន់អំណាចមួយក្រុមតូចក្នុងចង្កោមរដ្ឋាភិបាល ដែលធម្មតាតាមគោលការណ៍ច្បាប់ ក៏ដូចគោលការណ៍នៃការអប់រំព្រះពុទ្ធសាសនា ត្រូវតែជាអង្គភាពអំណាចដែលរលំរលាយ បាត់ទៅវិញនៅគ្រាណាមួយប៉ុណ្ណោះទេ ក៏ប៉ុន្តែវាជាកង្វល់ ជាពិសេសរបស់ប្រជារាស្ត្រខ្មែរជាទូទៅដែលកំពុងត្រូវគេមើល

តទៅទំព័រទី៤ ក

**តមកពីទំព័រទី១ ឡ**

បង្គោលលេខ១៨៥នោះបានធ្វើឱ្យរដ្ឋាភិបាលយួន ផ្តល់សញ្ជាតិឱ្យពលរដ្ឋខ្មែររស់នៅតាមតំបន់ព្រំដែន ដើម្បីកុំឱ្យតវ៉ានៅពេលបោះបង្គោលព្រំដែនដែលធ្វើឱ្យបាត់បង់ដីស្រែ ចំការ របស់ពួកគាត់ទៀតនោះ ។

ការលេចចេញ នូវព័ត៌មានដែលថា អាជ្ញាធរយួន បានផ្តល់សញ្ជាតិអោយប្រជាពលរដ្ឋខ្មែរដែលរស់នៅ តាមតំបន់ព្រំដែននេះក៏ផ្តើមចេញពីលោក *សម រង្ស៊ី* ប្រធានគណបក្សសម រង្ស៊ី ដឹកនាំចលនាមហាជនមួយ ទៅដកតម្រុយបង្គោលព្រំដែនលេខ១៨៥ចេញពីដីកសិករខ្មែរកាលពីខែតុលា ឆ្នាំ២០០៩ កន្លងទៅនេះ ។

លោក*យឹម សុវណ្ណ* អ្នកនាំពាក្យគណបក្សសម រង្ស៊ី បានមានប្រសាសន៍ ពាក់ព័ន្ធទៅនឹងករណីនេះ ប្រាប់*ខ្មែរម្ចាស់ស្រុក*ថា "*សព្វថ្ងៃប្រជាពលរដ្ឋ មិនហ៊ាននិយាយទេ ទោះបីជាវៀតណាមបោះបង្គោលព្រំដែន នៅក្នុងទឹកដីខ្មែរក៏ដោយ ប៉ះពាល់ដីប្រជាកសិករក៏ដោយ...ទីមួយខ្លាចជាប់ពន្ធនាគារ ហើយទីពីរទៀតគាត់បានចូលសញ្ជាតិវៀតណាម បើទោះបីជាដីគាត់ នៅក្នុងទឹកដីវៀតណាម ក៏គាត់មិនបាត់បង់ដីដែរ*" ។

ការថ្លែង របស់លោក *យឹម សុវណ្ណ* យ៉ាងដូច្នេះ ដោយសារតែមានប្រជាពលរដ្ឋខ្មែរ ចំនួន២នាក់ គឺលោកស្រី *មាស ស្រី* និងលោក *ព្រំ ជា* ជាកសិកររស់នៅភូមិកោះក្បានកណ្តាល ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង ត្រូវបានអាជ្ញាធរខ្មែរចាប់ដាក់ពន្ធនាគារ ដោយសារពួកគាត់ចូលរួមដកតម្រុយបង្គោលព្រំដែនលេខ១៨៥ ដែលធ្វើឱ្យបាត់បង់ដីស្រែរបស់ពួកគាត់អស់ ជាច្រើនហិកតានោះ ។

ការផ្តល់សញ្ជាតិយួន អោយដល់ពលរដ្ឋខ្មែរ របស់អាជ្ញាធរយួននេះ ដោយសារតែយួនដឹងថាបើទោះបីជាការបោះបង្គោលព្រំដែនចូលទៅក្នុងដីស្រែ របស់គាត់នៅក្នុងទឹកដីយួនក៏យួនទុកឱ្យដដែល ពីព្រោះមានសញ្ជាតិយួន ។ ម្យ៉ាងទៀតប្រជាពលរដ្ឋទាំងនោះ ទទួលបានផលប្រយោជន៍ច្រើនពីការចូលសញ្ជាតិយួននេះ ។

លោក*យឹម សុវណ្ណ* បានមានប្រសាសន៍ថា "*គាត់(ប្រជាពលរដ្ឋ) ទទួលបានផលប្រយោជន៍ច្រើន ពីប្រទេសវៀតណាមដូចជាការ ព្យាបាលជម្ងឺ មិនយកប្រាក់ កូនគាត់ ទៅសាលារៀនមិនយកប្រាក់ ហើយការទទួលបាន នូវការប្រើប្រាស់ អគ្គិសនីនិងផ្លូវថ្នល់...ជាពិសេសការប្រើអគ្គិសនីមានតម្លៃថោកបំផុត ។ ដូច្នេះ ប្រទេសវៀតណាម គេទាក់ទាញ ឱ្យប្រជាពលរដ្ឋខ្មែរយើងហ្នឹង បាក់ទឹកចិត្ត ទៅលើគេ ស្រឡាញ់គេ...នឹងភ្លេចថាអ្វីដែលគេកំពុងធ្វើ ប្រទេសគេកំពុងធ្វើហ្នឹង ធ្វើឱ្យបាត់បង់បូរណភាពទឹកដីរបស់យើង ។ ដូច្នេះ មានតែរដ្ឋាភិបាលទេ ដែលត្រូវតែ គិតគូរផលប្រយោជន៍ជាតិ ខិតខំប្រឹងប្រែងធ្វើម៉េចពន្យល់ប្រជាពលរដ្ឋឱ្យយល់អំពីគ្រោះថ្នាក់នៃការបាត់បង់ទឹកដី របស់យើងដែលយើងធ្លាប់ជួបប្រទះនៅក្នុងប្រវត្តិសាស្ត្រ ច្រើនឆ្នាំមកហើយ, ហើយនៅសល់តែប៉ុន្មានថ្ងៃទៀតហ្នឹង ខួបលើកទី៦១ ឆ្នាំនៃការបាត់បង់ ទឹកដីកម្ពុជាក្រោម ជាប្រវត្តិសាស្ត្រដ៏ជូរចត់ ដែលយើងត្រូវគិតអំពីបញ្ហាហ្នឹង*" ។

ការព្រួយបារម្ភ ចំពោះការបន្តបាត់បង់ ទឹកដីបន្ថែមទៀតទៅប្រទេសជិតខាង ជាពិសេសទៅប្រទេសយួននោះ ដូចជារដ្ឋឬប្រជាពលរដ្ឋបានលក់ដីឱ្យទៅក្រុមហ៊ុនមួយដែលមានព្រំដែនជាប់ជាមួយកម្ពុជា, ហើយនៅពេលបោះបង្គោលព្រំដែនច្បាស់ជាក្រុមហ៊ុននោះ មិនប្រតិកម្មទេ បើសិនជាកម្ពុជាបាត់បង់ទឹកដី ចូលទៅក្នុង ប្រទេសពួកគេនោះ ។

លោក*យឹម សុវណ្ណ* បានមានប្រសាសន៍ថា "*មានដីតំបន់ព្រំដែនខ្លះ លក់ទៅឱ្យក្រុមហ៊ុនបរទេសពេលដែលបោះបង្គោលព្រំដែនទោះបីជាប៉ះចំទៅលើក្រុមហ៊ុនហ្នឹង...គេមិនចាំបាច់អី ទៅតវ៉ាទេ ដែលនេះ ជាគ្រោះថ្នាក់មួយ ដែលរដ្ឋាភិបាល ចេះតែអះអាងថា គ្មានការតវ៉ា,ហើយមិនមានការតវ៉ា មិនមែនមានន័យថា មិនបាត់បង់ទឹកដី នោះទេ,មិនមានការតវ៉ាគឺមានមូលហេតុច្រើន*" ។

ភាពមិនប្រក្រតីដែលថាយួនបានផ្តល់សញ្ជាតិ ឱ្យពលរដ្ឋខ្មែររស់នៅតាមព្រំដែនដើម្បីមិនឱ្យប្រជាពលរដ្ឋ ដែលបាត់បង់ ដីស្រែដោយសារការបោះបង្គោលព្រំដែននេះ ក៏កើតមាននៅភូមិអន្លង់ជ្រៃ ឃុំអន្លង់ជ្រៃ ស្រុកពញាក្រែកខេត្តកំពង់ចាមដែលជា ស្រុកកំណើត របស់លោក *ហេង សំរិន* ប្រធានរដ្ឋសភានិងជា ប្រធានកិត្តិយស គណបក្សប្រជាជនដែរ ។ បញ្ហានេះ បានកើតមាននៅត្រង់បង្គោលឡាក់លេខ១២០តែម្តង ។

លោក*យឹម សុវណ្ណ* បានមានប្រសាសន៍ ពាក់ព័ន្ធ នឹងស្រុកកំណើតលោក*ហេង សំរិន* នេះថា "*ខ្ញុំកំពុងតាមដានព័ត៌មាន នៅបង្គោលឡាក់លេខ១២៥ មានបញ្ហាហ្នឹង មានការលេចឮព័ត៌មានហ្នឹង ។ យើងធ្លាប់ជួបបញ្ហាហ្នឹង នៅឃុំដូង ស្រុករមាសហែក...*" ។

សូមបញ្ជាក់ថា លោក *ហេង សំរិន* ធ្លាប់បានប្រាប់ ក្រុមអ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ី ក្នុងពិធីខួបកំណើតលោកកាលពីឆ្នាំ២០០៩ថា លោកធ្វើលំនៅដ្ឋានចែកជូនប្រជាពលរដ្ឋ និងការជីកប្រឡាយទឹកនៅក្នុងភូមិកំណើតលោកនោះ បានធ្វើឱ្យអ្នកខ្លះ មិនសប្បាយចិត្តទៅនឹងទង្វើរបស់លោកទេ ។ម្យ៉ាងការធ្វើនេះ គឺដើម្បីការពារព្រំដែនសីមាប្រទេសកម្ពុជាផងដែរ ។

ពាក្យថា គេមិនសប្បាយចិត្តនោះ ត្រូវបានគេយល់ថាលោក *ហេង សំរិន* និយាយសំដៅទៅប្រទេសយួន ៕

**តមកពីទំព័រទី១ ម**

ទៅជួបសួរសុខទុក្ខជនរងគ្រោះបាត់បង់ដីស្រែ ដែលកំពុងជាប់ពន្ធនាគារខេត្តស្វាយរៀង យ៉ាងអយុត្តិធមិនេះ ។

កាលពីថ្ងៃទី២០ ខែឧសភា ២០១០ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី បានចេញលិខិតមួយដោយសំដែងនូវការសោកស្តាយចំពោះការទាត់ ចោលសំណើរបស់ក្រុមអ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី នេះ,ហើយហៅការហាមឃាត់នេះថាជាការលំអៀង របស់ស្ថាប័នរដ្ឋ ។ លិខិតមានខ្លឹមសារដូចតទៅ :

អ្នកតំណាងរាស្ត្ររបស់គណបក្សសម រង្ស៊ី សំដែងនូវការសោកស្តាយយ៉ាងខ្លាំង ចំពោះតុលាការនិងក្រសួងមហាផ្ទៃដែលបានបន្ទុចបង្អាក់ អ្នកតំណាងរាស្ត្រគណបក្សសម រង្ស៊ី មិនឱ្យទៅសួរសុខទុក្ខ ប្រជាកសិករ២រូប គឺលោកស្រី *មាស ស្រី* និងលោក*ព្រំ ជា* ជាជនរងគ្រោះដែលបានបាត់បង់ដីស្រែ ដោយសារការបោះតម្រុយ បង្គោលព្រំដែន លេខ១៨៥ នៅពន្ធនាគារខេត្តស្វាយរៀង ។

គណបក្សសម រង្ស៊ី បានស្នើជាបន្តបន្ទាប់ ទៅតុលាការ និងក្រសួងមហាផ្ទៃ ដើម្បីសុំការអនុញ្ញាត ចូលជួបសួរសុខទុក្ខលោកស្រី*មាស ស្រី* និងលោក*ព្រំ ជា* ប៉ុន្តែពុំមានការឆ្លើយតបនោះទេ ។ ជាក់ស្តែងនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១០ គណបក្សសម រង្ស៊ី បានស្នើសុំ ទៅប្រធានសាលាដំបូង ខេត្តស្វាយរៀង តែត្រូវបដិសេធ ដោយឆ្លើយថា ជាសមត្ថកិច្ចរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។ នៅថ្ងៃទី១១ ឧសភា ២០១០ គណបក្សសម រង្ស៊ី បានស្នើសុំទៅអគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍តែត្រូវអគ្គព្រះរាជអាជ្ញាបដិសេធទៀតដោយស្នើអោយគណបក្សសម រង្ស៊ី សុំទៅអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃវិញ ។នៅថ្ងៃទី១៨ខែឧសភា ឆ្នាំ២០១០ គណបក្សសមរង្ស៊ីស្នើសុំទៅក្រសួងមហាផ្ទៃ តាមការចង្អុលបង្ហាញរបស់អគ្គព្រះរាជអាជ្ញា តែរហូតមកដល់ពេលនេះ គណបក្ស សម រង្ស៊ី មិនទាន់ទទួលបាន ការឆ្លើយតប ពីក្រសួងមហាផ្ទៃនៅឡើយដែរ ។

ការមិនអនុញ្ញាតនេះបង្ហាញអោយឃើញច្បាស់ អំពីភាពលំអៀងនៃស្ថាប័នរដ្ឋ ទៅលើគណបក្សកាន់អំណាច ដែលរំលោភបំពានលើសិទ្ធិជាធរមាន របស់អ្នកតំណាងរាស្ត្រ ក៏ដូចជាសិទ្ធិរបស់ប្រជាពលរដ្ឋទូទៅក្នុងការចូលទៅសួរសុខទុក្ខអ្នកជាប់ពន្ធនាគារ ហើយជាការប្រឆាំងនឹងកាតព្វកិច្ច និងភារកិច្ចរបស់អ្នកតំណាងរាស្ត្រដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

លិខិត ដាច់ដោយឡែកមួយទៀតរបស់លោកស្រី*កែ សុវណ្ណរតន៍* អ្នកតំណាងរាស្ត្រមណ្ឌលសៀមរាប កាលពីថ្ងៃទី១៧ ខែឧសភា ២០១០ បានស្នើលោក *អង្គ វង្សវឌ្ឍានា*រដ្ឋមន្ត្រីក្រសួងយុត្តិធមិ ធ្វើអន្តរាគមន៍អោយមានការដោះលែងប្រជាពលរដ្ឋចំនួន១២រូប ដែលកំពុងជាប់ឃុំឃាំង នៅពន្ធនាគារខេត្តសៀមរាប ដោយសារករណី ទំនាស់ដីស្រែប្រាំង ស្ថិតក្នុងភូមិសាស្ត្រ ស្រុកជីក្រែង ខេត្តសៀមរាប ។

លិខិតបានសរសេរថា ពាក់ព័ន្ធនឹងករណីទំនាស់ដីស្រែប្រាំង ស្ថិតក្នុងភូមិសាស្ត្រ នៃស្រុក ជីក្រែង ខេត្តសៀមរាប ដែលឈានរហូតដល់ កើតមានអំពើហិង្សាប្រដាប់អាវុធ កាលពីខែមីនា ឆ្នាំ២០០៩ កន្លងទៅនេះ ខ្ញុំជាអ្នកតំណាងរាស្ត្រ សង្កេតឃើញថា ក្នុងនាមក្រសួងយុត្តិធមិ ឯកឧត្តមបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះករណីនេះ ដោយបានផ្ញើលិខិតចំនួន៣ច្បាប់ជាបន្តបន្ទាប់ ទៅសាលាដំបូងខេត្ត សៀមរាប-ឧត្តរមានជ័យ ឱ្យចាត់ការសំណុំរឿងនេះ ទៅតាមនីតិវិធីច្បាប់ ។ ជាមួយគ្នានេះដែរ អាជ្ញាធរមានសមត្ថកិច្ចកំពុងតែដោះស្រាយ ករណីនេះ ប៉ុន្តែប្រជាពលរដ្ឋ ចំនួន១២រូប ត្រូវបានចាប់ និងឃុំខ្លួន ជាបន្តបន្ទាប់ ដោយសារករណីទំនាស់ដីស្រែប្រាំងនេះ ទោះបីជាមានការអន្តរាគមន៍ របស់ឯកឧត្តមផ្ទាល់ ក៏ដូចជាក្រសួងមហាផ្ទៃ និងស្ថាប័ន ពាក់ព័ន្ធ មួយចំនួនទៀតក៏ដោយ ។ បច្ចុប្បន្នប្រជាពលរដ្ឋទាំង១២រូប កំពុងមានជម្ងឺជាប់ខ្លួននិងអស់សង្ឃឹមយ៉ាងខ្លាំង ។ចំណែកក្រុមគ្រួសាររបស់ពួកគាត់វិញ បាននិងកំពុងជួបប្រទះនឹងការលំបាកផ្នែកជីវភាពរស់នៅប្រចាំថ្ងៃយ៉ាងខ្លាំងដោយពុំមានអ្នកប្រកបមុខរបរចិញ្ចឹមគ្រួសារ ។

អាស្រ័យដូចបានជម្រាបជូនខាងលើខ្ញុំសូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជួយធ្វើអន្តរាគមន៍អោយមានការដោះលែង ប្រជាពលរដ្ឋចំនួន១២រូប ដែលកំពុងជាប់ឃុំឃាំង នៅក្នុងពន្ធនាគារខេត្តសៀមរាប ដោយសារករណី ទំនាស់ដីស្រែប្រាំងនេះអោយមានសេរីភាពឡើងវិញ ស្របតាមអនុសាសន៍សម្តេច*ហ៊ុន សែន* នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលមិនឱ្យប្រជាពលរដ្ឋណាម្នាក់ ជាប់ពន្ធនាគារដោយសារទំនាស់ដីធ្លីឡើយ ៕

**តមកពីទំព័រទី១ ញ**

*អ៊ុម សិទ្ធី* ដើម្បីចាត់ការភាពមិនប្រក្រតីនៅក្នុងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅនេះផង ។

ភាពមិនប្រក្រតី ឬហៅថាសើមមាត់ខ្លាំងពេក នាំឱ្យធុំក្លិនមិនសូវស្រួលនៅក្នុងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅនោះត្រូវបានក្រុមមន្ត្រីលាតត្រដាងតាមរយៈលិខិតអនាមិកមួយច្បាប់ដូចខាងក្រោមនេះ :

១-បញ្ហាសម្ភារៈប្រឡងឆមាសលើកទី១ និងលើកទី២ និងប្រឡងសញ្ញាបត្រមធ្យមសិក្សាជាតិ ទាំងពីរកម្រិតថ្នាក់ ដែលលោក *អៀម ស៊ីផាត* ជាអនុប្រធាននាយកដ្ឋានហើយនៅតែកាន់កាប់សម្ភារៈ ព្រោះមួយឆ្នាំៗពុករលួយមិនតិចជាង១០ម៉ឺនដុល្លារហើយលោក*ច្រឹង លឹមស្រ៊ី* បានសើមមាត់ជារៀងរាល់ឆ្នាំ ហេតុនេះហើយបានជាគាត់ឱ្យលោ *អៀម ស៊ីផាត* ធ្វើព្យុះធ្វើភ្លៀង ហើយបើនរណាម្នាក់ហ៊ានតវ៉ាពីរឿងសម្ភារៈ លោក *ច្រឹង លឹមស្រ៊ី* និយាយកាន់ជើងលោក *អៀម ស៊ីផាត* រហូត ។មន្ត្រីរាជការនៅនាយកដ្ឋានមធ្យមសិក្សាភាគច្រើនមិនពេញចិត្តលោក *អៀម ស៊ីផាត* ទេ មានតែមន្ត្រីតាមអែបតាមអបគាត់មួយក្តាប់តូចប៉ុណ្ណោះពេញចិត្តគាត់ ។

២-ការប្រើប្រាស់ឡាន : លោក *អៀម ស៊ីផាត* បានយកឡានរបស់នាយកដ្ឋានពីរទៅប្រើប្រាស់សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួននៅលើកទី១ រថយន្ត Land Rover ប្រើប្រាស់លែងកើតទើបយកមកប្រគល់ឱ្យនាយកដ្ឋានវិញ និងលើកទី២ រថយន្ត Jeep Cherokee ពណ៌ទឹកប៊ិច ដែលក្រុមគ្រួសារគាត់កំពុងប្រើប្រាស់ចំណែកខ្លួនគាត់ពុំដែលឃើញជិះឡាន Jeep Cherokee មកធ្វើការទេ គាត់ជិះឡានតម្លៃជិត១០ម៉ឺនដុល្លារដែលបានមកពីអំពើពុករលួយសម្ភារៈប្រឡងមួយឆ្នាំៗ ព្រមទាំងមានដីរាប់សិបហិកតា ភូមិគ្រឹះ និងព្រមទាំងចិញ្ចឹមស្រីកំណាន់រាប់ភ្លេច វាផ្ទុយពីច្បាប់ឯកពន្ធភាព ។ ឥឡូវលេចឮព័ត៌មានច្បាស់ការណ៍ថាលោក*ច្រឹង លឹមស្រ៊ី* កំពុងរត់ការឱ្យលោក *អៀមស៊ីផាត*ឡើងកាន់តំណែងជំនួសកៅអីរបស់គាត់ ។

៣-បញ្ហាកូនបង្កើតលោក *ច្រឹង លឹមស្រ៊ី* ឈ្មោះ *ច្រឹង សោភ័ណ* បំរើការងារនៅនាយកដ្ឋានមធ្យមសិក្សាពីមុននៅការិយាល័យប្រឡងស្រាប់តែក្រោយមកដកមកដាក់នៅការិយាល័យរដ្ឋបាលវិញ ព្រោះលោក *ច្រឹង សោភ័ណ* បានប្រឡងជាប់ជាមន្ត្រីគយ ។នេះជាកលល្បិចលោក *ច្រឹង លឹមស្រ៊ី* ចង់ឱ្យកូនគាត់ធ្វើការពីរកន្លែង តើមនុស្សម្នាក់អាចធ្វើការពីរកន្លែងបានទេ? ហេតុនេះហើយបានជារដ្ឋាភិបាលបាននឹងកំពុងធ្វើជំរឿនមន្ត្រីរាជការទាំងអស់ដើម្បីរកមុខរកមនុស្សណាដែលធ្វើការពីរកន្លែងដូចលោក*ច្រឹង សោភ័ណ* ជាកូនបង្កើតលោក *ច្រឹង លឹមស្រ៊ី* អញ្ចឹង យើងខ្ញុំកំពុងរង់ចាំមើលការធ្វើជំរឿននៅពេលខាងមុខនេះ តើឈ្មោះ *ច្រឹង សោភ័ណ* ធ្វើជំរឿនខាងក្រសួងអប់រំ ឬខាងក្រសួងសេដ្ឋកិច្ច?

៤-ការចុះផ្សាយត្រកូល *ច្រឹង* នៅក្នុងសារព័ត៌មានកន្លងមកជារឿងពិតព្រោះនៅនាយកដ្ឋានមធ្យមសិក្សាចំណេះដឹងទូទៅ ត្រកូល *ច្រឹង* មាន៤នាក់ គឺ *ច្រឹង លឹមស្រ៊ី*, *ច្រឹង ចៅកែវ*, *ច្រឹង ស៊ុនលី*និង*ច្រឹងសោភ័ណ* ។

រហូតមកដល់ពេលនេះពុំឃើញមានចំណាត់ការចំពោះត្រកូល *ច្រឹង* ពីរដ្ឋមន្ត្រីក្រសួងអប់រំនៅឡើយទេ ។នេះប្រហែលជាលោក *អ៊ុម សិទ្ធី* បានលាបសក្ការៈពីលោក *ច្រឹង លឹមស្រ៊ី* ហើយបានជាមិនចាត់ការ ។

ទាក់ទិនទៅនឹងសំណើរបស់ក្រុមមន្ត្រីដែលបំរើការងារនៅតាមនាយកដ្ឋានក្រោមឱវាទក្រសួងអប់រំនេះត្រូវបានលោក *រ៉ុង ឈុន* ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យធ្វើជាលិខិតមួយច្បាប់កាលពីថ្ងៃទី២០ ខែឧសភា ផ្ញើជូនលោករដ្ឋមន្ត្រី *អ៊ុម សិទ្ធី* ដោយស្នើសុំឱ្យមានការស៊ើបអង្កេតលើករណីភាពមិនប្រក្រតីពាក់ព័ន្ធជាមួយប្រធាន និងអនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះដឹងទូទៅនោះ ។

លិខិតលោក *រ៉ុង ឈុន* បានរៀបរាប់ថា តាមខ្លឹមសារនៅក្នុងលិខិតអនាមិកដែលបានចោទប្រកាន់លោកប្រធាននិងលោកអនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅបានប្រព្រឹត្តអំពើពុករលួយជាង១០ម៉ឺនដុល្លារក្នុងមួយឆ្នាំៗទៅលើសម្ភារៈប្រលងឆមាសទី១ ទី២ និងប្រឡងសញ្ញាបត្រមធ្យមសិក្សាថ្នាក់ជាតិទាំងពីរកម្រិត ។ដោយឡែកនូវក្នុងលិខិតអនាមិកនេះក៏បានចោទប្រកាន់ថ្នាក់ដឹកនាំនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅថា បានយកឡានរបស់នាយកដ្ឋានប្រើប្រាស់សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនទៀតផង ។

ករណីអំពើពុករលួយនៅក្នុងនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅក្រសួងអប់រំយុវជននិងកីឡា ត្រូវបើកការស៊ើបអង្កេតបន្ទាន់ដើម្បីរកមុខជនដែលប្រព្រឹត្តអំពើពុករលួយយកមកផ្តន្ទាទោសតាមច្បាប់ ។សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យគិតថា លិខិតអនាមិកនេះជាមូលដ្ឋានសម្រាប់ក្រសួងធ្វើការស៊ើបអង្កេតករណីអំពើពុករលួយនេះ ព្រោះតាមការសិក្សា និងសន្និដ្ឋានលើលិខិតអនាមិកបានចង្អុលបង្ហាញពីការពិតអំពីភាពមិនប្រក្រតីជាច្រើននៅក្នុងនាយកដ្ឋានមធ្យមសិក្សា ៕

**ផ្សព្វផ្សាយពាណិជ្ជកម្ម លើទំព័រសារព័ត៌មានខ្មែរម្ចាស់ស្រុក**
**សូមទាក់ទងមកកាន់**
**ទូរស័ព្ទ : 017 360 678**
**ទូរសារ : 023 987 411**

**តមកពីទំព័រទី១ ស**

នៅពីក្រោយខ្នងបាតុករអាវក្រហម ដែលបានដុតបំផ្លាញអគារជាច្រើន នៅទីក្រុងបាងកក ក៏ដូចជា នៅតាមបណ្តាខេត្តនានា នៃប្រទេសសៀម ។

លោក ថាក់ស៊ិន ត្រូវបានប្រមុខរដ្ឋាភិបាលកម្ពុជាលោកហ៊ុន សែន ស្នើព្រះមហាក្សត្រ ព្រះបរមនាថ នរោត្តម សីហមុនី តែងតាំង ជាទីប្រឹក្សា រាជរដ្ឋាភិបាល និងជាទីប្រឹក្សា លោក (ហ៊ុន សែន) ផ្ទាល់ ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច ។

ដូច្នេះការចោទប្រកាន់របស់អាប់ភីស៊ិត ថា លោកថាក់ស៊ិន ជាមេភេរវិករនេះ ក៏ដូចជាបានចោទទីប្រឹក្សាម្នាក់របស់លោកហ៊ុន សែន ថា ជាមេភេរវិករដែរ ។ ប៉ុន្តែគេមិនដឹងថា តើលោកហ៊ុន សែន នឹងបន្តរក្សាទុកឱ្យ មេភេរវិករ (តាមការចោទប្រកាន់របស់អាប់ភីស៊ិត) ថាក់ស៊ិន ធ្វើជាទីប្រឹក្សាដដែលទៀត ឬគាត់បណ្តេញចេញ ដូចទីប្រឹក្សាគាត់ នាពេលកន្លងមកនោះទេ ។

លោកហ៊ុន សែន ក៏ដូចជាលោកហេង សំរិន ប្រធាន រដ្ឋសភានិងលោកជា ស៊ីម ប្រធានព្រឹទ្ធសភាដែរដែលអ្នកទាំងបីគឺសុទ្ធតែមានទីប្រឹក្សាម្នាក់ៗរាប់ សិបនាក់ឯណោះ ។

លោកហ៊ុន សែន ក៏ធ្លាប់បានបណ្តេញទីប្រឹក្សាម្នាក់ ផ្នែកសន្តិសុខជាតិដែរ ហើយសព្វថ្ងៃនេះកំពុងជាប់ពន្ធនាគារ ដែលតុលាការរកឃើញថាគាត់មានទោសត្រូវជាបនពន្ធនាគារ ដល់ទៅជាង៩០ឆ្នាំ ។ ទីប្រឹក្សារូបនោះឈ្មោះហេង ពៅ ។ ប៉ុន្តែសំរាប់លោកថាក់ស៊ិនដែលរដ្ឋាភិបាលក្រុងបាងកកចោទប្រកាន់ថាជាមេភេរវិករនោះ នឹងត្រូវលោកហ៊ុន សែន ដកចេញពីតំណែងឬយ៉ាងណាទេ ។

មិនថាតែ លោកហ៊ុន សែន ធ្លាប់ដកលោកហេង ពៅ ចេញពីទីប្រឹក្សារបស់គាត់ទទួលបន្ទុកផ្នែកសន្តិសុខជាតិនោះទេ សូម្បីតែលោកជា ស៊ីម និងលោកហេង សំរិន ក៏ធ្លាប់ដកទីប្រឹក្សាគាត់ចេញខ្លះដែរនៅពេលដែលទីប្រឹក្សាពួកគាត់ ធ្លាយចេញនូវរឿងអាស្រូវនោះ ។

លោកជា ស៊ីម ធ្លាប់បានបណ្តេញលោកដេវីដ ឆាណារ៉ា ពីទីប្រឹក្សាគាត់ផងដែរ កាលពីប៉ុន្មានឆ្នាំមុន នៅពេលដែលដឹងថា មេធាវីរូបនេះ មានរឿងអាស្រូវ ដូចជាបើករថយន្ត ហាំម័រចតលើសួនច្បារ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន ក្បែរមាត់ទន្លេ ដែលធ្វើឱ្យគាត់ ជាប់ពន្ធនាគារទៀតផង ។ ក្រោយមកមេធាវីមកពី អាមេរិក រូបនេះក៏មានរឿងអាស្រូវ បាញ់បោះនៅក្នុងហាងផឹកស៊ី ក្នុងទីក្រុងភ្នំពេញផងដែរ ។

លោកជា ស៊ីម ក៏ធ្លាប់មានទីប្រឹក្សាម្នាក់ឈ្មោះ ជេន ជីលី ជនជាតិចិន ហើយរហស្សនាមជាមេម៉ាហ្វីយ៉ាអន្តរជាតិ ។ ជេន ជីលី នេះ ក៏ត្រូវបានអាជ្ញាធរខ្មែរឃាត់ខ្លួន នៅក្នុងភូមិគ្រឹះមួយក្នុងទីក្រុងភ្នំពេញ , ហើយបុគ្គលម្នាក់នេះ ក៏មានងារ ជាឧកញ៉ាខ្មែរដែរ ។

លោកហេង សំរិន ក៏ធ្លាប់មានទីប្រឹក្សាជាថៅកែសិប្បកម្មគ្រឿងញៀនដ៏ធំ នៅខេត្តកំពង់ស្ពឺដែរគឺឧកញ៉ាអ៊ំ ឆាយ ។ ឧកញ៉ាអ៊ំ ឆាយ ត្រូវបានអាជ្ញាធរចាប់ខ្លួនបាន កាលពី ខែសីហា ឆ្នាំ២០០៧ ហើយយកទៅ ឃុំខ្លួន នៅការិយាល័យ អាជ្ញាធរជាតិ ប្រឆាំងបទល្មើស ជួញដូរគ្រឿងញៀន ដែលក្រោយមកត្រូវអាជ្ញាធរអះអាងថាឧកញ៉ាអ៊ំ ឆាយ ធ្វើអត្តឃាត ដោយលោតចេញ ពីបន្ទប់ឃុំខ្លួន នៅជាន់ទី២ បណ្តាលឱ្យគាត់ ស្លាប់នៅនឹងកន្លែង ។

បន្ទាប់ពីរឿងអាស្រូវ របស់ឧកញ៉ាអ៊ំ ឆាយ នេះធ្លាយចេញជាសាធារណៈមក,លោកហេង សំរិន ក៏បានដកតួនាទីឧកញ៉ាអ៊ំ ឆាយ ពីទីប្រឹក្សាផងដែរ ប៉ុន្តែការដកនេះ នៅពេលដែល ឧកញ៉ាអ៊ំ ឆាយ បានស្លាប់បាត់ទៅហើយនោះ ។

សំរាប់លោកថាក់ស៊ិនដែលជា ទីប្រឹក្សា រដ្ឋាភិបាលកម្ពុជា និងជាទីប្រឹក្សាលោកនាយករដ្ឋមន្ត្រីហ៊ុនសែនទទួលបន្ទុកផ្នែកសេដ្ឋកិច្ចនេះ គេមិនទាន់ដឹងថាតើលោកហ៊ុន សែន មានផែនការដកគាត់ចេញពីទីប្រឹក្សាដែរឬអត់នោះទេ បើរដ្ឋាភិបាល ទីក្រុងបាងកក ចោទប្រកាន់គាត់ថា ជាមេភេរវិករហើយនោះ ។

លោកថាក់ស៊ីនមិនមែនមានងារ ត្រឹមតែជាមេភេរវិករ ដូចការចោទប្រកាន់ របស់មេដឹកនាំទីក្រុងបាងកកនោះទេ, គាត់ថែមទាំងត្រូវតុលាការសៀមរកឃើញថា មានទោសពីបទពាក់ព័ន្ធនឹងអំពើពុករលួយ កាលពីគាត់នៅកាន់តំណែង ជានាយករដ្ឋមន្ត្រីមកម្លេះ ។

ដូច្នេះបើលោកហ៊ុនសែនបន្តរក្សាតំណែងលោកថាក់ស៊ិនជាទីប្រឹក្សាគាត់និងជាទីប្រឹក្សារាជរដ្ឋាភិបាលបន្តទៀតនោះ មានន័យថា ប្រទេសកម្ពុជាសព្វថ្ងៃខ្វះធនធានមនុស្ស ធ្វើការច្រើនណាស់ បានជាយកមនុស្សដែលរដ្ឋាភិបាលប្រទេសជិតខាង គេចោទថា ជាមេភេរវិករ ឱ្យធ្វើទីប្រឹក្សាខ្លួនឯងផ្ទាល់ និងជាទីប្រឹក្សារាជរដ្ឋាភិបាលនោះ ៕

---

**តមកពីទំព័រទី១ ខ**

កាល័យគឺព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ ។

ឥឡូវសម្តេចឪ សព្វព្រះទ័យទទួលយកលោកខែក វ៉ាន់ឌី ជាទីប្រឹក្សាផ្ទាល់របស់ព្រះអង្គ ជាផ្លូវការហើយ ។ ប៉ុន្តែការទទួលយកលោកខែក វ៉ាន់ឌី នេះ ក៏នៅរង់ចាំ ព្រះរាជក្រឹត្យ របស់ព្រះមហាក្សត្រ ព្រះបរមនាថ នរោត្តម សីហមុនី ដែរ ។

មន្ត្រី ព្រះបរមរាជវាំងម្នាក់បានអោយដឹងថា សម្តេចឪបានសព្វព្រះទ័យ ឱ្យមានទីប្រឹក្សានៅពេលនេះជាភាពចម្លែកមួយដែលតាំងពីព្រះអង្គ បានយាងចូលនិវត្តន៍មក ព្រះអង្គតែងតែគង់រក្សានៅកន្លែងណា ដែលជាភាពស្ងប់ស្ងាត់ ដូចជាព្រះរាជដំណាក់ នៅអង្គរវត្ត ខេត្តសៀមរាប, ការយាងទៅប្រទេសចិនដើម្បីព្យាបាលព្រះរោគ ។

លោកខែក វ៉ាន់ឌី ជាអតីតមន្ត្រីរាជរដ្ឋាភិបាល នៃសម័យសង្គមរាស្ត្រនិយមហើយលោកមានស្វាមីភក្តិ ជាមួយសម្តេចឪ សម្តេចម៉ែ និងក៏ជា ស្ថាបនិកគណបក្សហ្វ៊ុនស៊ិនប៉ិច កាលពីសម័យតស៊ូបណ្តេញទាហានយួនឈ្លានពានផងដែរ ។

លោកខែក វ៉ាន់ឌី ជាអតីតមន្ត្រីហ្វ៊ុនស៊ិនប៉ិចម្នាក់ដែលរក្សាគោលជំហរ ស្មោះត្រង់ ដង្ហែសម្តេចឪជានិច្ច ទោះបីជាមានព្រឹត្តិការណ៍ បណ្តេញ សម្តេចក្រុមព្រះ ពីហ្វ៊ុនស៊ិនប៉ិច កាលពីថ្ងៃទី១៨ ខែតុលា ២០០៦ ក៏ដោយ ។

មន្ត្រីព្រះបរមរាជវាំង បានអោយដឹងថា តួនាទីលោកខែក វ៉ាន់ឌី នេះ មានកិត្តិយស ជាងសម្តេចក្រុមព្រះ ឆ្ងាយណាស់ ដែលព្រះអង្គជាប្រធានឧត្តមទីប្រឹក្សា របស់ព្រះមហាក្សត្រ ។ តំណែង របស់សម្តេចក្រុមព្រះនេះ ត្រូវបានគេមើលឃើញថាជាតំណែង ដែលដោះដូរ ណាមួយជាមួយអ្នកនយោបាយក្នុងការលាចេញពីនយោបាយ ។

សូមបញ្ជាក់ថាសម្តេចឪព្រះនរោត្តម សីហនុ មានទីប្រឹក្សាច្រើនណាស់កាលពីព្រះអង្គគង់ជាព្រះមហាក្សត្រ ។ ប៉ុន្តែនៅក្រោយពីព្រះអង្គបានយាងចូលនិវត្តន៍មក ក៏គ្មានទីប្រឹក្សាដែរ គឺទើបតែពេលនេះទេ ដែលព្រះអង្គ សព្វព្រះទ័យ ទទួលយកលោកខែក វ៉ាន់ឌី ជាទីប្រឹក្សាផ្ទាល់, ហើយក៏ជា ទីប្រឹក្សាតែម្នាក់គត់ដែរ ៕

---

**តមកពីទំព័រទី៤ ៩**

កម្ពុជាជាក់ស្តែងសព្វថ្ងៃថាអ្វីៗធ្វើឡើងនៅក្រោមអំណាចឥទ្ធិពលរបស់គណបក្ស និងបក្ខពួករបស់អ្នកមានអំណាច ។ លោកបានបន្តរៀបរាប់ថា "ស្ថាប័នផ្សេងៗដូចជាតុលាការ សភាជាតិ ក៏ត្រូវជាស្ថាប័នឯករាជ្យក្នុងការបំពេញតួនាទី ។ សភាជាតិយើងដែលជាស្ថាប័នមានតួនាទីតាមដានការងាររបស់រដ្ឋាភិបាល ថវិកាជាតិ ប្រាក់កម្ចីពីគេ សាងសង់សមិទ្ធិផលផ្សេងៗ សមិទ្ធិផលរបស់ជាតិដែលចេញពីថវិកាជាតិមិនមែនថវិការបស់បុគ្គលរបស់បក្សទេ" ។

លោកបានបន្តវែកញែកទៀតថា ក្នុងស្ថានភាពដែលមេដឹកនាំប្រទេសមិនយល់ ឬធ្វើមិនយល់ "អំពីការទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រទេស វាធ្វើឱ្យសាលារៀនមួយចំនួនក្លាយទៅជាឈ្មោះបុគ្គល ។ បើយើងធ្វើសំណួរយ៉ាងខ្លីថា តើអស់លោកបានលុយមកពីណាសាងសង់សាលាហ្នឹង ? ប្រាក់ខែអស់លោកប៉ុន្មាន ? ហេតុអ្វីគេចេះតែយកលុយមកឱ្យអស់លោក?ពីព្រោះមានការនិយាយសព្វថ្ងៃថា មាននយោបាយវប្បធម៌នៃការរួមចំណែក ។ ហ្នឹងជាពាក្យដែលគេថា ។ប៉ុន្តែហេតុអ្វីគេរួមចំណែកតែជាមួយក្រុមអ្នកមានអំណាច ? " ។

គឺជាការថ្លែងអធិប្បាយដល់ពាក្យដែលនាយករដ្ឋមន្ត្រីតែងថ្លែងជាសាធារណៈនៅឯពិធីនានាក្នុងការទទួលលុយជួយពីអ្នកឧកញ៉ាសេដ្ឋីនេះនោះ ឬមន្ត្រីជាន់ខ្ពស់ហែរហមគាត់ប៉ុណ្ណោះម៉ឺនដុល្លារ ប៉ុណ្ណោះសែនដុល្លារ ជាមួយពាក្យរបស់គាត់ថា "សិល្បៈនៃការចែករំលែក "ដោយមិនមានការពន្យល់ច្បាស់លាស់ថាប្រភពលុយនោះបានមកពីណានោះទេ ក្នុងគ្រាដែលធនធានធម្មជាតិរបស់ប្រទេសចេះតែបន្តរងការបំផ្លិចបំផ្លាញអន្តរាយ ហើយឃើញតែគំនរទ្រព្យសម្បត្តិរបស់ពួកអ្នកមានអំណាច និងសេដ្ឋីឧកញ៉ា ឈ្មួញមួយចំនួនតូចនោះ ។

ហើយតើវប្បធម៌រួមចំណែកឬសិល្បៈនៃការចែករំលែកនោះមានអ្វីជាប្រយោជន៍ដល់ប្រទេសជាតិឬទេ ? លោក សុន ឆ័យ បានផ្តល់ចម្លើយចំពោះសំណួរនេះថា "ជាអំពើមួយដែលខាតប្រយោជន៍ជាតិ ។ ឧទាហរណ៍ ក្រុមហ៊ុនមួយគេហ៊ានផ្តល់ទៅឱ្យនាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីណាមួយដើម្បីសាងសង់អគារដាក់ឈ្មោះរដ្ឋមន្ត្រីហ្នឹង ។ គឺគេធ្វើការរកស៊ីជាមួយរដ្ឋមន្ត្រីហ្នឹង ។ ទី១គេមិនបង់ពន្ធ ។ បើគេត្រូវបង់ពន្ធឱ្យរដ្ឋយើងមួយលានដុល្លារ នោះគេសុខចិត្តឱ្យ២០ម៉ឺនដុល្លារ សាងសង់សាលារៀន ។ ទី២ គេអត់បានបង់៨សែនដុល្លារ " ។

រឿងនេះលោកបានបញ្ជាក់បន្ថែមថា គេអាចក្លាយជាមេដោយគេសួរពួកមន្ត្រីពន្ធដារថាតើពួកគេហ៊ានទៅជិតសំណង់ទាំងឡាយនោះដែរឬទេ ដើម្បីនឹងរកការពិតថា ប្រាក់សាងសង់នោះបានមកពីប្រភពណាដែលជាទម្លាប់ធម្មតានៅប្រទេសប្រកាន់គោលការណ៍ច្បាប់ប្រជាធិបតេយ្យសេរីនោះ ស្ថាប័នឯករាជ្យរបស់ប្រទេសមានសមត្ថកិច្ចក្នុងរឿងនេះនិងធ្វើការស៊ើបអង្កេតស្រាវជ្រាវ ។

ជាមួយគ្នានោះដែរលោក សុន ឆ័យ បានថ្លែងកត់សម្គាល់នូវអ្វីជាការមើលឃើញរបស់ពួកអ្នកសង្កេតការណ៍ និងរបស់សាធារណៈជនអំពីចំនួនមេដាយឧកញ៉ា និងងារឯកឧត្តមឃើញកើតមានព្រោងព្រាតក្នុងស្ថានភាពសង្គមកម្ពុជាបច្ចុប្បន្នលោកបានមានប្រសាសន៍ដល់មេដាយនិងងារជាឧកញ៉ា ដែលពួកអ្នកទាំងនោះ "គេយកឥទ្ធិពលហ្នឹងដើម្បីមិនបង់ពន្ធជូនរដ្ឋតាមច្បាប់ ។ គឺគេចំណេញពន្ធ ។ បើយើងកុំឱ្យយក១០ភាគរយដែលគេបង់ឱ្យយើងយក១០០ភាគរយមកដាក់ថវិកាជាតិរបស់យើងថាយកទៅសង់សាលារៀនវិញនោះ យើងបានចំនួនសាលាពី ៥ ទៅ១០ដងលើសនេះ ។ នេះខាតលុយកាក់ទី១ ហើយទី២គឺខាតពាក់ព័ន្ធនឹងការលើកទឹកចិត្តដល់សីលធម៌ល្អ ឬយុត្តិធម៌នៅក្នុងសង្គម " ។

ត្រង់ចំណុចនេះលោក សុន ឆ័យ បានអធិប្បាយបន្ថែមថា អ្វីដែលជាហេតុផលនោះ គឺពួកមន្ត្រីដែលគេមិនបង់ពន្ធត្រឹមត្រូវនោះ ក៏គេមានសិទ្ធិពិសេសណាស់ ទាំងសិទ្ធិនៃការយកងារតំណែងទាំងអស់នោះទៅប្រព្រឹត្តល្មើសច្បាប់ "ដូចជាសិទ្ធិដីធ្លីសិទ្ធិសម្បទានដីធ្លី សិទ្ធិរបស់គាត់ក្នុងការធ្វើអ្វីៗដោយមិនខ្លាចញញើតច្បាប់ ។ វាធ្វើឱ្យគាត់អស់នោះមានឥទ្ធិពលយ៉ាងសម្បើមក្នុងសង្គម " ។ លោកបានបញ្ជាក់បន្តថាការគ្រប់គ្រងសង្គមស្ថានភាពបច្ចុប្បន្ននៅកម្ពុជាឱ្យកិត្តិយសទៅអ្នកដែលមានលុយកាក់ខ្ពស់សម្បើមណាស់ ហើយអ្នកដែលមានសមាណចិត្ត និងសេចក្តីទៀងត្រង់ក្នុងការបំរើផលប្រយោជន៍ជាតិដោយមិនមានទម្លាប់សូកប៉ាន់ ឬដោយកម្លាំងវិធីនយោបាយផ្សេងៗនោះ ពុំត្រូវបានបរិយាកាសសង្គមកម្ពុជាសព្វថ្ងៃផ្តល់កិត្តិយសឱ្យឡើយ ។

ជាហេតុផលនោះលោក សុន ឆ័យ បានថ្លែងថា "គេបានឃើញនៅក្នុងប្រទេសកម្ពុជា មានមេដាយច្រើនណាស់ ។ ឧកញ៉ាក៏ច្រើន ហើយងារឯកឧត្តមគេទិញបានទាំងអស់ ។ងារឯកឧត្តម ទីប្រឹក្សាក៏ដោយ គេយកលុយទៅទិញដើម្បីបង្កើតឈ្មោះ បង្កើតងារ ដើម្បីយកអំណាចទៅរកស៊ីទៅលុបបំបាត់នូវស្ថានភាព នៃសិទ្ធិទាំងឡាយរបស់ពលរដ្ឋ " ។

អំពីរឿងនេះលោកបានមើលឃើញស្របគ្នានឹងការកត់សម្គាល់របស់មជ្ឈដ្ឋានអ្នកសង្កេតការណ៍ ទាំងម្ចាស់ជំនួយផងដែរ អំពីការបាត់បង់នូវលុយកាក់ដ៏ច្រើនសន្ធឹកសន្ធាប់របស់ប្រទេសកម្ពុជាតាមទម្លាប់និងស្ថានភាពបែបខាងលើ ។ លោកបានបន្តវែកញែកថា "បើធ្វើដោយត្រឹមត្រូវ កុំតាមរយៈវប្បធម៌រួមចំណែកហ្នឹង លោកឯងត្រូវបង់ពន្ធប៉ុណ្ណា ឱ្យបង់ស្មើគ្នា ហើយការរកស៊ីប្រណាំងប្រជែងគ្នាត្រឹមត្រូវផង ហើយរដ្ឋមានសេចក្តីសម្រេចថាឱ្យសម្បទានដល់ក្រុមហ៊ុនណាមួយដែលមានការដេញថ្លៃ " ។

អ្វីជារបៀបគ្រប់គ្រងប្រទេសកម្ពុជាសព្វថ្ងៃ ជាអត្តសញ្ញាណសម្គាល់អំណាចនយោបាយរបស់គណបក្សប្រជាជនដែលមានលោកនាយករដ្ឋមន្ត្រី ហ៊ុនសែន ជាអ្នកដឹកនាំនោះ គឺការពង្រឹងវប្បធម៌ដែលភាសានយោបាយសកលពិពណ៌នាថា "វប្បធម៌សក្ការៈបុគ្គល " លោកសុន ឆ័យបានពន្យល់ថានេះជាដំណើរគ្រោះថ្នាក់របស់ប្រទេស ។លោកបានលើកឡើងជាសំណួរថា មនុស្សមានអាយុកាលកំណត់ដោយពេលវេលា ខុសពីអាយុជីវិតប្រទេសជាតិមួយដែលត្រូវនៅយូរអង្វែង ដូច្នេះ "ចុះបើអស់ពីបុគ្គលនោះ តើសង្គមជាតិប្រទេសជាតិនឹងទៅជាយ៉ាងណា ? " ។

ជាចម្លើយនោះលោកបានចង្អុលទៅរកបទពិសោធន៍ដែលប្រទេសទាំងឡាយនៅលើពិភពលោកនេះឆ្លងកាត់ហើយក៏មានការប្រកាន់យកនូវគោលការណ៍ប្រជាធិបតេយ្យ" មានការគ្រប់គ្រងប្រទេសបែបប្រជាធិបតេយ្យ" ។

ការគ្រប់គ្រងប្រទេសតាមប្រព័ន្ធនេះដែលកំពុងមានឥទ្ធិពលរីករាលដាលពាសពេញពិភពលោក នោះតាមការអធិប្បាយរបស់លោក សុន ឆ័យ គេមិននិយាយតែត្រឹមការបោះឆ្នោតមួយទេ ។ ដែលហៅថាប្រជាធិបតេយ្យគឺមានការបោះឆ្នោតមួយដោយភាពត្រឹមត្រូវជាមួយស្ថាប័នជាតិមួយដែលល្អដែរ ។

លោក សុន ឆ័យ បានលើកយកករណីជាឧទាហរណ៍"គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការឱ្យបានត្រឹមត្រូវមិនប្រកាន់បក្ខពួក ។ មន្ត្រីរាជការទាក់ទងនឹងស្ថាប័នរដ្ឋបាលខេត្តស្រុកផ្សេងៗធ្វើការដើម្បីជាតិ ជាសមាជិករបស់រដ្ឋ មិនមែនរបស់គណបក្សទេ " ។

ហើយស្ថានភាពដែលកំពុងញាំញីក្លាយជាវប្បធម៌នៃការពង្រឹងអំណាចបុគ្គលនិងអំណាចរបស់បក្ខពួកមួយនៅកម្ពុជាបច្ចុប្បន្ន ក៏ត្រូវបានលោក សុន ឆ័យ លើកឡើងមកបញ្ជាក់ថា "តាំងពីប្រធានភូមិឡើង តាមសង្កេតមើលថា តើសមាជិកក្នុងភូមិគាត់ពេញចិត្តក្រុមណា ។ បើគាត់មិនពេញចិត្តបក្សរបស់ខ្លួនទេ អំណោយក៏មិនឱ្យ ការបោះឆ្នោតក៏មិនឱ្យបានបោះឆ្នោត " ដែលរបៀបនេះត្រូវបំបាត់ចោលភ្នាក់ងារបក្សហ្នឹង ហើយត្រូវបង្កើតឱ្យមានស្ថាប័នដែលមន្ត្រីជាសមាជិកមានភារកិច្ចផ្តល់សេវាដល់ពលរដ្ឋដោយត្រឹមត្រូវ ។

សម្រាប់លោក សុន ឆ័យ ប្រធានក្រុម នៃសមាជិកសភាគណបក្សសមរង្ស៊ីនោះ ដើម្បីបញ្ចប់វប្បធម៌នៃការរួមចំណែក ឬតាមពាក្យរបស់នាយករដ្ឋមន្ត្រីថា "សិល្បៈនៃការចែករំលែក " ដែលធ្វើឱ្យបាត់បង់ថវិកាជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ពីការត្រូវរ៉ូវគ្នារវាងអ្នកកាន់អំណាច និងពួកឈ្មួញក្រុមហ៊ុនឯកជនទាំងឡាយនោះប្រទេសកម្ពុជាត្រូវរៀបចំខ្លួនដោយការពង្រឹងស្ថាប័នរដ្ឋ ក៏ដូចជាច្បាប់ឱ្យត្រឹមត្រូវ ពីព្រោះវប្បធម៌នៃការរួមចំណែកនោះធ្វើឱ្យប្រទេសជាតិជាអ្នកខាតបង់យ៉ាងច្រើន ហើយក៏ជាគ្រោះថ្នាក់ចំពោះប្រទេសកម្ពុជាផងដែរ ៕

**ក្រុមហ៊ុនភាពយន្ត ជនបទ**
**មានទទួលបញ្ចាំង ខ្សែភាពយន្តខ្នាតធំ ក្នុងពិធីផ្សេងៗ មានពន្លឺច្បាស់ និងមានលក់ម៉ាស៊ីន បញ្ចាំងខ្សែភាពយន្ត ទំនាក់ទំនងតាមទូរស័ព្ទ**
**012 66 44 67**
**015 66 44 67**

Khmer Machas Srok News
ការិយាល័យនិពន្ធ
Tel : 017 360 678
Fax : 023 987 411
E-mail: kmsnews@gmail.com
www.kmsdaily.blogspot.com
ផ្នែកផ្សាយពាណិជ្ជកម្ម
017 360 678

សារព័ត៌មាន "ខ្មែរម្ចាស់ស្រុក" ប្រចាំថ្ងៃ ទំព័រទី០៤
Tel: 017 360 678 , E-mail: kmsnews@gmail.com

តមកពីទំព័រទី១ ន

ការកែប្រែណាមួយក្នុងកិច្ចការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះទេ។

លោក *យឹម សុវណ្ណ* បានមានប្រសាសន៍បន្តទៀតថា "*ខ្ញុំគិតថា អំពើពុករលួយមិនបានថយចុះឡើយនៅពេលដែលលោកឱម យ៉ិនទៀង បានធ្វើជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយថ្មីនៅទីស្តីការគណៈរដ្ឋមន្ត្រីនោះ* "។

លោកបានសង្កត់ធ្ងន់ថា លោកមិនរំពឹងថា នឹងមានការកែប្រែណាមួយអាចកើតឡើងនោះទេ ព្រោះកន្លងមកលោកក៏ជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយនៅទីស្តីការគណៈរដ្ឋមន្ត្រីដែរ តើលោកបានធ្វើអ្វីខ្លះក្នុងការប្រឆាំងនឹងអំពើពុករលួយ ? ហើយការតែងតាំងថ្មីនេះទៀតសោត ក៏គ្មានអ្វីគួរឱ្យចម្លែកដែរ។

លោក *យឹម សុវណ្ណ* បានធ្វើការកត់សម្គាល់ថា អំពើពុករលួយមានតែរីករាលដាលធំឡើងៗថែមទៀតប៉ុណ្ណោះ "*ហើយខ្ញុំជឿថា នឹងគ្មានការកែប្រែណាមួយនៅក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ* "ឡើយ។

គួររំលឹកថាTheCambodia Daily បានដកស្រង់សម្តីលោក *ឱម យ៉ិនទៀង* មកចុះផ្សាយកាលពីថ្ងៃទី២០ ខែឧសភាថា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ *នរោត្តម សីហមុនី* បានតែងតាំងលោកជាផ្លូវការអស់រយៈពេលជិត២អាទិត្យមកហើយ ដោយឱ្យលោកធ្វើជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយថ្មីរបស់រដ្ឋាភិបាល ដែលជាផ្នែកមួយយ៉ាងសំខាន់នៃស្ថាប័នជាតិប្រឆាំងនឹងអំពើពុករលួយពោលគឺក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ។

ក្នុងនាមជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយលោក *ឱម យ៉ិនទៀង* បាននិយាយថា ព្រះមហាក្សត្រ *នរោត្តម សីហមុនី* បានឡាយព្រះហស្ថលេខាលើការតែងតាំងលោក បន្ទាប់ពីលោក *ហ៊ុន សែន* នាយករដ្ឋមន្ត្រី នៃប្រទេសកម្ពុជាបានស្នើតែងតាំងលោកដោយអនុលោមទៅតាមនីតិវិធីដែលបានលម្អិតក្នុងច្បាប់ប្រឆាំងអំពើពុករលួយ។

លោក *ឱម យ៉ិនទៀង* បានបញ្ជាក់បន្ថែមទៀតថា "*ព្រះមហាក្សត្របានតែងតាំងខ្ញុំឱ្យដឹកនាំអង្គភាពប្រឆាំងអំពើពុករលួយថ្មី។ ដូច្នេះខ្ញុំនឹងខិតខំធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះដោយម៉ត់ចត់បំផុត*"។

លោកបានអធិប្បាយថា "*ខ្ញុំនឹងអានច្បាប់ និងអនុវត្តច្បាប់នេះ ព្រមទាំងសហការធ្វើការងារជាមួយអង្គការអន្តរជាតិនានាដើម្បីអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព* "។

លោក *ឱម យ៉ិនទៀង* ព្យាយាមនិយាយដើម្បីឱ្យគេជឿថា "*ខ្ញុំនឹងចូលរួមក្នុងការធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ច យុត្តិធមិ និងច្បាប់ ។នេះគឺជាបេសកកម្មពិតប្រាកដនៃអង្គភាពប្រឆាំងអំពើពុករលួយ* "។

ក្រុមអ្នកសង្កេតការណ៍នានាបានលើកមកនិយាយថា កន្លងមកលោក *ឱម យ៉ិនទៀង* ក៏ជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយដែរ តែដូចជាមិនឃើញធ្វើអ្វីដើម្បីឱ្យអំពើពុករលួយនៅក្នុងប្រទេសកម្ពុជាមានការថយចុះឡើយ។

លើកមុនគេបានរិះគន់រដ្ឋាភិបាលលោក*ហ៊ុន សែន* ថា ខណៈដែលច្បាប់ប្រឆាំងអំពើពុករលួយមិនទាន់ទាំងលេចចេញជារូបរាងផង រដ្ឋាភិបាលបានបង្កើតឱ្យមានអង្គភាពប្រឆាំងអំពើពុករលួយប្រចាំទីស្តីការគណៈរដ្ឋមន្ត្រីទៅហើយ ដោយតែងតាំងលោក *ឱម យ៉ិនទៀង* ឱ្យធ្វើជាប្រធានដឹកនាំអង្គភាពមួយនេះ។

គេថា ក្នុងនាមជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លោក *ឱម យ៉ិនទៀង* មិនបានធ្វើឱ្យប្រសើរឡើងចំពោះអំពើពុករលួយដែលកំពុងរីករាលដាលឡើយ។

ដូច្នេះនៅពេលដែលមានច្បាប់ប្រឆាំងអំពើពុករលួយហើយក៏គួរតែរដ្ឋាភិបាលលោក *ហ៊ុន សែន* តែងតាំងអ្នកណាដែលគេមានឆន្ទៈក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយឱ្យមកដឹកនាំអង្គភាពប្រឆាំងអំពើពុករលួយទើបជាការប្រសើរ, តែបើដាក់លោក *ឱម យ៉ិនទៀង* ដដែលនោះ គឺគ្មានវាចាអ្វីដែលត្រូវថ្លែងទៀតទេ។

The Cambodia Daily បានសរសេរកាលពីថ្ងៃម្សិលមិញថា ដំណឹងស្តីពីការតែងតាំងលោក *ឱម យ៉ិនទៀង* នេះ ទើបនឹងដឹងកាលពីថ្ងៃពុធ ទី១៩ ខែឧសភាទេ ខណៈដែលស្ថាប័នព្រឹទ្ធសភាបានប្រកាសថា ព្រឹទ្ធសភាកំពុងស្វែងរកបេក្ខជនម្នាក់ដោយខ្លួនឯងដើម្បីកាន់តំណែងមួយនៅឯក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយដែលពួកគេមិនទាន់បានបង្កើតឡើងផងនោះ។

លោក *អ៊ុំ សារិទ្ធ* អគ្គលេខាធិការព្រឹទ្ធសភាបានថ្លែងថាការស្វែងរកបេក្ខជនម្នាក់ត្រូវបានចាប់ផ្តើមជ្រើសរើសដោយយកចិត្តទុកដាក់បំផុត។ ហើយថា "*យើងកំពុងតែស្វែងរកបេក្ខជនម្នាក់ដោយយោងតាមច្បាប់ប្រឆាំងអំពើពុករលួយ។ ព្រឹទ្ធសមាជិកដែលនឹងត្រូវជ្រើសរើសនោះនឹងត្រូវបោះឆ្នោតជាសម្ងាត់ដោយព្រឹទ្ធសមាជិកទាំងអស់*"។

ក្នុងនោះសេចក្តីប្រកាសរបស់ព្រឹទ្ធសភា គឺតម្រូវឱ្យបេក្ខជនមានអាយុមិនលើសពី៤៥ឆ្នាំ និងមានបទពិសោធន៍ការងារ១០ឆ្នាំនៅក្នុងសភា, ក្រមសីលធមិល្អនិងបានបញ្ចប់ថ្នាក់ឧត្តមសិក្សា។

ទោះជាយ៉ាងនេះក្តីក៏លោក *យឹម សុវណ្ណ* អ្នកនាំពាក្យគណបក្សសមរង្ស៊ីបានលើកហេតុផលថា លោកមិនជឿថា ព្រឹទ្ធសភាដែលលើសលប់ដោយគណបក្សប្រជាជនកម្ពុជានោះ នឹងបោះឆ្នោតឱ្យបេក្ខជនឯករាជ្យណាម្នាក់នោះទេ។

លោកបានធ្វើការកត់សម្គាល់ថា ព្រឹទ្ធសភានឹងជ្រើសរើសបេក្ខជនដែលជាសមាជិកគណបក្សប្រជាជនកម្ពុជា។ ម្យ៉ាងទៀតលោកសុំឱ្យរដ្ឋសភាគួរតែកែប្រែច្បាប់ប្រឆាំងអំពើពុករលួយដើម្បីអនុញ្ញាតឱ្យមានសមាជិកឯករាជ្យច្រើនទៀតនៅក្នុងក្រុមប្រឹក្សាជាតិប្រឆាំងនឹងអំពើពុករលួយ។

មុននេះបន្តិចលោក *គង់ គាំ* ប្រធានស្តីទីគណបក្សសមរង្ស៊ីបានមានប្រសាសន៍ប្រាប់សកម្មជនគណបក្សសមរង្ស៊ីដោយត្រង់ៗថា "*ច្បាប់ប្រឆាំងអំពើពុករលួយដែលគេបានអនុម័តហើយនេះ វាស្មើនឹងមានន័យថា ជាច្បាប់កុំប្រឆាំងនឹងអំពើពុករលួយ*"៕

---

តមកពីទំព័រទី១ ខ

បញ្ហា អ្នកនយោបាយជាន់ខ្ពស់ជាសមាជិកសភាពីគណបក្សប្រឆាំងដ៏ធំបំផុតនៅកម្ពុជាបានពិពណ៌នាថា នេះជាសញ្ញានៃដំណើរគ្រោះកាចអាក្រក់សម្រាប់ប្រទេស។

លោក *សុន ឆ័យ* ប្រធានក្រុមនៃសមាជិកសភាគណបក្សសមរង្ស៊ី ជាគូប្រជែងដ៏ខ្លាំងតែមួយគត់ទល់នឹងគណបក្សប្រជាជននៃលោកនាយករដ្ឋមន្ត្រីនោះ លោកបានធ្វើការកត់សម្គាល់អំពីវប្បធមិនៃការដែលមេដឹកនាំប្រទេសអះអាងជុំវិញពាក្យ "*សិល្បៈនៃការចែករំលែក* " ហើយដែលនៅក្នុងនោះមានការស៊ីគ្រលំគ្នាទទួលយកលុយពីឈ្មួញមន្ត្រីទាំងឡាយទៅសាងសង់សាលារៀន និងអ្វីៗដាក់ឈ្មោះខ្លួនឯង ហើយធ្វើឱ្យរដ្ឋបាត់ពន្ធច្រើនដងលើសការបានទទួលនោះ។ លោក *សុន ឆ័យ* បានមានប្រសាសន៍ថា ស្ថានភាពប្រទេសកម្ពុជាឥឡូវ "*ការដែលមេដឹកនាំទទួលបន្ទុកលើសេចក្តីសម្រេចចិត្តលើរឿងរ៉ាវរបស់ប្រទេសជាតិស្ទើរតែគ្រប់ករណី សម័យនេះប្លែកដោយសារអំណាចបុគ្គលគ្របដណ្តប់លើស្ថាប័នជាតិទាំងអស់ ។ហ្នឹងជារឿងគ្រោះថ្នាក់សម្រាប់ប្រទេសជាតិ* "។

លោកបានបន្តអធិប្បាយវែកញែកថា ការគ្រប់គ្រងប្រទេសមួយមិនអាចរំពឹងលើបុគ្គលម្នាក់ ទោះបីជាឧបមាថាបុគ្គលនោះមានបញ្ញាឈ្លាសវៃជ្រៅជ្រះ និងធ្វើការបានផលឆាប់ទទួលជោគជ័យក៏ដោយ ពីព្រោះនេះជាដំណើរមួយផ្ទុយនឹងចរន្តធម្មជាតិរបស់ពិភពលោក ក៏ដូចជាការគ្រប់គ្រងប្រទេសនីមួយៗ ជាពិសេសប្រទេសមួយមានអាយុកាល ហើយមនុស្សដែលមានលទ្ធភាព សុខភាពទោះបីថ្នាក់ដឹកនាំប្រទេសជាតិដ៏មហាអស្ចារ្យក៏វានៅមានកម្រិតពេលវេលាដែរ។

លោកបានបន្តអធិប្បាយអំពីស្ថានការណ៍វិវឌ្ឍន៍នៃសង្គម

តទៅទំព័រទី៣ ខ

---

តមកពីទំព័រទី១ ក

ឃើញថា ជាជនរងគ្រោះដោយបញ្ហានានាកើតមានពាសពេញប្រទេស។ ហើយអ្នកដែលជាសាក្សីដ៏សំខាន់នៅក្នុងរឿងនេះ គឺម្ចាស់ជំនួយអន្តរជាតិ រាប់ទាំងអង្គការសហប្រជាជាតិខ្លួនឯងផង ដូចដែលមានការសិក្សាស្រាវជ្រាវនិងចេញរបាយការណ៍ជាហូរហែកត់សម្គាល់អំពីការធ្លាក់ខ្លួនចុះក្រនៃប្រជារាស្ត្រខ្មែរក្នុងស្ថានភាពនៃការវិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកម្ពុជាបច្ចុប្បន្នដែលគណបក្សប្រជាជនត្រួតត្រាប្រទេសប្រកាសអួតថាជាការរីកចំរើនសេដ្ឋកិច្ចសង្គមប្រែប្រួលយ៉ាងសម្បើមនោះ។

របាយការណ៍របស់អង្គការសហប្រជាជាតិបានកត់សម្គាល់ឃើញតាមការសិក្សាស្រាវជ្រាវរយៈពេលច្រើនឆ្នាំរបស់ខ្លួន ក៏ស្របគ្នានឹងការសិក្សារបស់ទីភ្នាក់ងារជំនួយអភិវឌ្ឍន៍អន្តរជាតិនានាសម្រាប់កម្ពុជាផងដែរអំពីប្រជារាស្ត្រខ្មែរដែលធ្លាប់រកចំណូលបាន១ម៉ឺនរៀលកាលនៅកាន់កាប់គ្រប់គ្រងដីដោយផ្ទាល់ជាចំនួនសម្រាប់មួយថ្ងៃៗឥឡូវនៅពេលដែលរដ្ឋាភិបាលគណបក្សប្រជាជនរឹបអូសយកដីធ្លីរបស់ពួកគាត់ក្រោមលេសសម្បទានសេដ្ឋកិច្ចប្រគល់ឱ្យក្រុមហ៊ុនឯកជនទាំងឡាយហើយគេអះអាងអំពីការជួយរកការងារឱ្យប្រជារាស្ត្រខ្មែរអស់ទាំងនោះ ពួកគាត់បែរជារកចំណូលបានក្នុងចន្លោះប្រមាណ៥ពាន់រៀលបន្តិចបន្តួចក្នុងមួយថ្ងៃៗ។ គ្មាននរណាដឹងថា នយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកាសអួតដោយរដ្ឋាភិបាលគណបក្សប្រជាជន ជាពិសេសរបស់ដែលហៅថាគោលនយោបាយចតុកោណកាត់បន្ថយភាពក្រីក្រថ្លែងដោយក្រុមកាន់អំណាចបច្ចុប្បន្ននៅស្រុកខ្មែរ និងរុញប្រជារាស្ត្រខ្មែរជាម្ចាស់ប្រទេស ដែលធ្លាប់ជាម្ចាស់ដីធ្លីឱ្យក្លាយទៅជាទាសករបាត់បង់ដីធ្លីហើយស៊ីឈ្នួលលក់ពលកម្មរំលោះជីវិតមួយថ្ងៃសម្រាប់តែមួយថ្ងៃក្នុងប្រទេសមួយដែលនឹងបាត់ឈ្មោះ ឬរលាយរូបនោះនៅពេលណា ឬក៏យ៉ាងណាឡើយ។

នៅគ្រប់ទីកន្លែងគេតែងតែបានឮការស្រែកយំរបស់ប្រជាកសិករ ជាពិសេសអ្នកក្រីក្រតូចតាចដែលរស់ពឹងពាក់លើដីធ្លីដើម្បីនឹងប្រាថ្នាទាមទារយុត្តិធម៌ពីរដ្ឋាភិបាលគ្រប់គ្រងប្រទេស ដោយសារបញ្ហាដែលពួកគាត់ប្រឈមនឹងការរឹបអូសយកដីធ្លីពីសំណាក់ក្រុមហ៊ុនឈ្មួញមានលុយ និងក្រុមមន្ត្រីធំៗមានអំណាចតំណែងទាំងឡាយ ។ហើយក្នុងប្រទេសកម្ពុជាដែលពលរដ្ឋជាង១០លាននាក់ ឬជាង៨០ភាគរយជាកសិករត្រូវរស់ពឹងពាក់ជីវិតលើដីធ្លី ប៉ុន្តែបែរជាខ្វះដីធ្លី ឬគ្មានដីធ្លី ហើយអ្នកមានដីធ្លី ក៏កំពុងត្រូវគេរឹបអូសយកទៀតនោះ តើប្រទេសកម្ពុជានឹងទៅជាយ៉ាងណា ហើយប្រជារាស្ត្រខ្មែរនឹងទៅជាជនជាតិអ្វី ?

សំណួរនេះមិនមែនជាការលើកឡើងបំផុសដោយកាសែតខ្មែរម្ចាស់ស្រុក សម្រាប់តែការទាក់ទាញការយកចិត្តទុកដាក់របស់មជ្ឈដ្ឋានពាក់ព័ន្ធទាំងឡាយនោះទេ ប៉ុន្តែក៏គឺជាការកត់សម្គាល់របស់អ្នកកាសែតអន្តរជាតិ និងសូម្បីតែអតីតសមាជិកក្រុមប្រឹក្សារដ្ឋនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលបានចាកចេញពីគណបក្សនេះទៅរស់នៅបរទេសហើយដោយឡែកគឺប្រជារាស្ត្រខ្មែរជាសំខាន់នោះក៏ចាប់អារម្មណ៍នៃដំណើរវិវឌ្ឍន៍នៃសង្គមខ្មែរបច្ចុប្បន្ននេះដែរ។

លោកបណ្ឌិត វ៉ាន់ ឌីកាអុន ដែលធ្លាប់ធ្វើជាសមាជិកក្រុមប្រឹក្សារដ្ឋ នៃរបបប្រជាមានិតកម្ពុជា ៧ មករា ១៩៧៩ ហើយដឹងកិច្ចការនយោបាយផ្ទៃក្នុងនៃរបៀបគ្រប់គ្រងរបស់គណបក្សប្រជាជនបដិវត្តកម្ពុជាជាឈ្មោះដើមរបស់គណបក្សប្រជាជនកម្ពុជាបច្ចុប្បន្ននោះ លោកបានសរសេរនូវសៀវភៅមួយសម្តែងកង្វល់ព្រួយអំពីវាសនារបស់ប្រទេសកម្ពុជា។គឺជាវណ្ណកម្មដែលមានចំណងជើងថា "ប្រទេសកម្ពុជាដែលមិនមែនខ្មែរ"។

អ្នកកាសែតអន្តរជាតិម្នាក់លោក ហ៊ីរិ កាំ ដែលធ្លាប់ធ្វើការជិត៥០ឆ្នាំឱ្យកាសែតអាមេរិកាំងដ៏ល្បីល្បាញ The New York Times ហើយដែលឥឡូវលោកបានចូលនិវត្តទៅហើយនោះ លោកធ្លាប់បានធ្វើសន្និសីទកាសែតមួយក្នុងបំណងទាក់ទាញអ្នកកាសែតអន្តរជាតិទាំងឡាយឱ្យយកចិត្តទុកដាក់ដល់កម្រិតខ្ពស់បំផុតចំពោះដំណើរនិងវាសនារបស់ប្រទេសកម្ពុជាឆ្ពោះទៅរកគ្រោះថ្នាក់។ នៅចំពោះមុខអ្នកកាសែតអន្តរជាតិស្រករក្រោយ លោក ហ៊ីរិ កាំ បានប្រឈមនឹងសំណួរថា តើលោកមើលឃើញវាសនារបស់ប្រទេសកម្ពុជាយ៉ាងណា ហើយលោកក៏បានផ្តល់ចម្លើយថា "ខ្ញុំមិនប្រាកដថាប្រទេសកម្ពុជានឹងនៅមាននោះទេ" ជាការអធិប្បាយក្នុងន័យអាចយល់បានយ៉ាងសាមញ្ញបំផុតថាប្រទេសកម្ពុជានឹងបាត់ឈ្មោះ ឬប្តូរម្ចាស់ចំពោះស្ថានភាពបែបនេះ។

នៅឯសន្និសីទកាសែតនោះដែរលោក ហ៊ីរិ កាំ បានថ្លែងថា"ប្រជារាស្ត្រខ្មែរសព្វថ្ងៃរស់នៅក្នុងឋាននរកមួយបែបចេញពីស្ថាននរកសម័យខ្មែរក្រហម ប៉ុល ពត"។ លោកបានវែកញែកថា ភោគទ្រព្យធនធានធម្មជាតិដែលជាផលប្រយោជន៍ប្រជារាស្ត្រខ្មែរទូទៅត្រូវបានក្នុងប្រទេសកម្ពុជាដ៏សំបូរសម្បត្តអស់ទាំងនេះ បែរជាត្រូវពួកអ្នកកាន់អំណាច និងពួកឈ្មួញមួយក្តាប់តូចបែងចែកប្រយោជន៍រវាងគ្នា។

ទោះជាយ៉ាងនេះក៏ដោយសម្រាប់គណបក្សកាន់អំណាចពោលគឺគណបក្សប្រជាជននិងនាយករដ្ឋមន្ត្រីហ៊ុន សែន ផ្ទាល់នោះ គេដូចជាពិបាកគិតថា គាត់មិននឹកនាដល់វាសនាគ្រោះកាចអាក្រក់របស់ប្រទេសកម្ពុជានោះណាស់ ពីព្រោះបើទោះបីជាមានចំណែកណាមួយគាត់ត្រូវគេស្តីបន្ទោសថា ទទួលរងឥទ្ធិពលលុយកាក់ និងគំនិតមហិច្ឆតាអំណាចយូរអង្វែងនៅលើប្រទេសកម្ពុជាក៏ដោយ ក៏គាត់ត្រូវតែគិតគូរដល់វាសនារបស់ប្រទេសកម្ពុជា។ ប៉ុន្តែទន្ទឹមនឹងនេះដែរ បើស្ថានការណ៍នៃការគ្រប់គ្រងប្រទេសបច្ចុប្បន្នឃើញតែប្រជារាស្ត្រនៅតាមតំបន់នានាដែររស់ពឹងពាក់លើដីធ្លី ត្រូវគេរឹបអូសយកដីធ្លីទៅប្រគល់ឱ្យក្រុមហ៊ុនឈ្មួញឯកជនទាំងឡាយ ហើយពួកគាត់ក៏ក្លាយទៅជាទាសករស៊ីឈ្នួលនៅលើដីស្រែចំការរបស់ពួកគាត់នោះ តើនរណាមិនអាចនឹងខ្វល់បានដល់វាសនារបស់ប្រទេសកម្ពុជា និងរបស់ជនជាតិខ្មែរនោះ ?៕

